ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

# នីតិវិធីប្រតិបត្តិស្តង់ដា
# ស្តីពី
# យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩




រៀបចំឡើងដោយ៖

អនុគណៈកម្មការបណ្តុះបណ្តាល និងត្រួតពិនិត្យបច្ចេកទេសចាក់វ៉ាក់សាំងកូវីដ-១៩

ខែ មិថុនា ឆ្នាំ ២០២១

## អារម្ភកថា

ស្ថានភាពជំងឺកូវីដ-១៩នៅប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននៅតែមានលក្ខណៈគួរឱ្យព្រួយបារម្ភ ដែលតម្រូវឱ្យយើងទាំងអស់គ្នាបង្កើនល្បឿនប្រឹងប្រែងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ។ ក្រៅពីការបន្តអនុវត្តវិធានការបង្ការការឆ្លងនៃជំងឺកូវីដ-១៩ “៣ការពារ និង៣កុំ” ការចាក់វ៉ាក់សាំងកូវីដ-១៩នឹងរួមចំណែកកាត់បន្ថយ ភាពធ្ងន់ធ្ងរនៃជំងឺ ការចូលសម្រាកពេទ្យ និង អត្រាមរណៈភាព ។ គ្មាននរណាម្នាក់មានសុវត្ថិភាពនោះទេ បើមនុស្សគ្រប់គ្នាមិនទាន់មានសុវត្ថិភាព។ ក្នុងន័យនេះដែរ ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជា បានបង្កើតគណៈកម្មការ ចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) ដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ រួមទាំងជនបរទេសដែលកំពុងរស់នៅ និងបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជាដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅយ៉ាងហោចណាស់១០លាននាក់ បានទទួលវ៉ាក់សាំងកូវីដ-១៩។

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ នឹងផ្តល់ការណែនាំលម្អិតជាជំហានៗ ស្តីពីការរៀបចំ និង ដំណើរការកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីឱ្យយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ មន្ត្រីសុខាភិបាល មន្ត្រីនៃបណ្តាអង្គភាពរដ្ឋនិងឯកជនដទៃទៀត រួមទាំងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា នឹងទទួលបានសារៈប្រយោជន៍ និងការណែនាំគន្លឹះចេញពីនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩មួយនេះ។

ក្នុងនាមប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមការងាររបស់អនុគណៈកម្មការបណ្តុះបណ្តាល និងត្រួតពិនិត្យបច្ចេកទេស នៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលបានខិតខំប្រឹងប្រែងចងក្រងនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ។ នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មន្ត្រីសុខាភិបាល និងមន្ត្រីពាក់ព័ន្ធទាំងអស់នឹងប្រើប្រាស់នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ ក្នុងការរៀបចំ និងដំណើរការកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដើម្បីឱ្យយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩បានសម្រេចជោគជ័យតាមផែនការ និងប្រកបដោយសុវត្ថិភាព។

ថ្ងៃចន្ទ ១២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩**
**ក្នុងក្របខណ្ឌទូទាំងប្រទេស**

វេជ្ជ. ឱ វណ្ណឌីន

# សេចក្តីថ្លែងអំណរគុណ

| | | |
|---|---|---|
| ១. ឯកឧត្តមសាស្ត្រាចារ្យ | **ហ៊ុន ចំរើន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២. ឯកឧត្តមវេជ្ជបណ្ឌិត | **ស៊ិក ប៊ុណ្ណា** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៣. ឯកឧត្តមវេជ្ជបណ្ឌិត | **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេសក្រសួងសុខាភិបាល |
| ៤. ឯកឧត្តមវេជ្ជបណ្ឌិត | **ស៊ុង វិនតះ** | ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្រសួងសុខាភិបាល |
| ៥. លោកឱសថការី | **ឱក វិជិត** | អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ៦. លោកវេជ្ជបណ្ឌិត | **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល |
| ៧. លោកវេជ្ជបណ្ឌិត | **គុំ សំសុង** | ប្រធាននាយកដ្ឋានបុគ្គលិកក្រសួងសុខាភិបាល |
| ៨. លោកវេជ្ជបណ្ឌិត | **កុយ វិរីយ៉ា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល |
| ៩. លោកស្រីវេជ្ជបណ្ឌិត | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាពក្រសួងសុខាភិបាល |
| ១០. លោកស្រីឱសថការី | **វ៉ា ពុធនាថ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្រសួងសុខាភិបាល |
| ១១. លោកសាស្ត្រាចារ្យរង | **អ៊ិរ ម៉** | នាយករងវិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| ១២. លោកឱសថការី | **ឆៀប ចាន់ថន** | អនុប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ |
| ១៣. លោកវេជ្ជបណ្ឌិត | **យុង ឧុឌ្ឍីកុល** | អនុប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ |
| ១៤. លោកស្រីវេជ្ជបណ្ឌិត | **ហួរ ដានេ** | អនុប្រធានការិយាល័យរដ្ឋបាល នៃមន្ទីរពេទ្យកុមារជាតិ |
| ១៥. លោកវេជ្ជបណ្ឌិត | **ទួន សុវណ្ណរិទ្ធិ** | វេជ្ជបណ្ឌិតឯកទេសមន្ទីរពេទ្យកាល់ម៉ែត |
| ១៦. លោកវេជ្ជបណ្ឌិត | **សោ ហុកបាន** | វេជ្ជបណ្ឌិតឯកទេសមន្ទីរពេទ្យកាល់ម៉ែត |
| ១៧. លោកទន្តបណ្ឌិត | **តែ វណ្ណារ័ត្ន** | មន្ត្រីវិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| ១៨. លោកគ្រូពេទ្យ | **ស៊ីផាន់ សុវណ្ណារ៉ា** | មន្ត្រីស្រាវជ្រាវជំងឺរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ |
| ១៩. លោកវេជ្ជបណ្ឌិត | **ឈឹន  វិសាលបញ្ញា** | មន្ត្រីនាយកដ្ឋានមន្ទីរពេទ្យ |

# មាតិកា


១. សេចក្ដីផ្ដើម ........ 1

២. គោលបំណង ........ 1

៣. មន្ត្រីទទួលបន្ទុក ........ 1

៤. ក្រុមប្រជាជនគោលដៅ ........ 5

៥. នីតិវិធីប្រតិបត្តិ ........ 6

៥.១. ការរៀបចំកន្លែងចាក់វ៉ាក់សាំង ........ 6

៥.២. ដំណើរការផ្ដល់វ៉ាក់សាំង ........ 10

៥.៣. ការគ្រប់គ្រងប្រព័ន្ធត្រជាក់ និងវ៉ាក់សាំង ........ 15

៥.៤. វិធានការអនាម័យ ការការពារខ្លួន និងការគ្រប់គ្រងសំណល់........ 16

៥.៥. ការពិនិត្យ តាមដាន និងគ្រប់គ្រងហេតុការណ៍កើតមានក្រោយចាក់វ៉ាក់សាំង........ 18

៥.៦. ការបណ្ដុះបណ្ដាល អភិបាល តាមដាន និងវាយតម្លៃ........ 20

ឧបសម្ព័ន្ធ ក........ 23

ឧបសម្ព័ន្ធ ខ........ 24

ឧបសម្ព័ន្ធ គ........ 25

ឧបសម្ព័ន្ធ ឃ ........ 27

## ១. សេចក្តីផ្តើម

កូវីដ-១៩ជាជំងឺឆ្លងបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី SARS-CoV-2។ ជំងឺកូវីដ-១៩បាននឹងកំពុងរាតត្បាតយ៉ាងខ្លាំងនៅក្នុងពិភពលោក។ ករណីជំងឺកូវីដ-១៩ដំបូងនៅកម្ពុជាត្រូវបានរកឃើញក្នុងខេត្តព្រះសីហនុ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ មកត្រឹមថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ នៅកម្ពុជា មានករណីជំងឺកូវីដ-១៩សរុបចំនួន ៤២ ៧១១ នាក់ ត្រូវបានរាយការណ៍ ក្នុងនោះមានករណីជាសះស្បើយ ៣៧ ៤៨៩ នាក់ និង ស្លាប់ ៤៣១ នាក់។ ក្រៅពីផលប៉ះពាល់លើសុខភាព និងអាយុជីវិតប្រជាពលរដ្ឋ ការរាតត្បាតនៃជំងឺនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គមនិងសេដ្ឋកិច្ច។

ការចាក់វ៉ាក់សាំងជាយុទ្ធសាស្ត្រមួយ ក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាល នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រជាពលរដ្ឋ ចំនួន ១០លាននាក់ សំដៅសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ និងបញ្ឈប់ការរំខានសង្គមនិងសេដ្ឋកិច្ច។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានប្រើប្រាស់យន្តការជាច្រើនដើម្បីទទួលបានវ៉ាក់សាំងកូវីដ-១៩ និងបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ជូនប្រជាពលរដ្ឋឱ្យបានលឿនបំផុតតាមតែអាចធ្វើទៅបាន។ នៅក្នុងកាលៈទេសៈនៃយុទ្ធនាការចាក់វ៉ាក់សាំងនេះ ការបន្តអនុវត្តវិធានការបង្ការការឆ្លងនៃជំងឺកូវីដ-១៩ ៣ការពារ (១-ពាក់ម៉ាស់ ២-អនាម័យដៃ និង ៣-រក្សាគម្លាតពីគ្នា១,៥ ម៉ែត្រ) និង ៣កុំ (១-កុំទៅកន្លែងបិទជិត គ្មានខ្យល់ចេញចូល ប្រើម៉ាស៊ីនត្រជាក់ច្រើនពេក ២-កុំទៅកន្លែងមនុស្សច្រើនកុះករ និង ៣-កុំប៉ះពាល់គ្នា ចាប់ដៃគ្នា កៀកស្មាគ្នា ឱបគ្នា) មានសារៈសំខាន់ជាសារវន្ត។

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ ផ្តល់ការណែនាំលម្អិត ជាជំហានៗ ស្តីពីការរៀបចំ និងដំណើរការកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ព្រមទាំងសកម្មភាពសំខាន់ៗពាក់ព័ន្ធនឹងយុទ្ធនាការចាក់ វ៉ាក់សាំងកូវីដ-១៩ ដល់មន្ត្រីសុខាភិបាល មន្ត្រីនៃបណ្តាអង្គភាពរដ្ឋនិងឯកជនដទៃទៀត និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ជាពិសេស មន្ត្រីបម្រើការនៅកន្លែងចាក់វ៉ាក់សាំង មន្ត្រីអភិបាល និង មន្ត្រីបណ្តុះបណ្តាល។

## ២. គោលបំណង

នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ មានគោលបំណងធានាឱ្យយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ដើម្បីឈានទៅកាត់បន្ថយការចម្លង ភាពធ្ងន់ធ្ងរនៃជំងឺ មរណៈភាព និងផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច។

## ៣. មន្ត្រីទទួលបន្ទុក

ដើម្បីឱ្យយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ រាជរដ្ឋាភិបាល បានបង្កើត *គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស* មួយ ដើម្បីទទួលខុស

ត្រូវរួមលើយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩នេះ។ រូបភាពទី១ បង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលក្នុងនោះ មន្ទីរពេទ្យជាតិ និង មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត ជាអ្នកទទួលបន្ទុកផ្ទាល់លើការរៀបចំ និងគ្រប់គ្រងកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមមូលដ្ឋានសុខាភិបាល ឬទីកន្លែងសមស្របផ្សេងទៀត។




*រូបភាពទី១៖ រចនាសម្ព័ន្ធគ្រប់គ្រងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩*

ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបពីតួនាទី-ភារកិច្ចរបស់ មន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និង អង្គភាពពាក់ព័ន្ធសំខាន់ៗ។

**តួនាទី-ភារកិច្ចរបស់មន្ទីរពេទ្យថ្នាក់ជាតិ**

- ជ្រើសរើសអ្នកសម្របសម្រួលមន្ទីរពេទ្យដែលនឹងត្រូវធ្វើការងារជិតស្និទ្ធជាមួយអ្នកសម្របសម្រួលដទៃទៀត និង ប្រធានក្រុមចាក់វ៉ាក់សាំង
- បូកសរុបការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការចាក់ឱ្យប្រជាជនគោលដៅ

- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗដែលរក្សាទុកបន្ទាប់ពីបានទទួលពីឃ្លាំងឱសថកណ្តាល ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
- ធានាថាមានធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) គ្រប់គ្រាន់ដើម្បីដំណើរការចាក់វ៉ាក់សាំង
- ចុងបញ្ចប់នៃថ្ងៃនីមួយៗ មន្ទីរពេទ្យត្រូវត្រួតពិនិត្យ (ការគ្របដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារ) និង ប្រាកដថាសកម្មភាពអនុវត្តបានត្រឹមត្រូវតាមបច្ចេកទេស
- ធានាថាបានរាយការណ៍ជាបន្ទាន់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
    - ✓ ហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង ព្រមទាំងការពិនិត្យព្យាបាល និងសង្គ្រោះបន្ទាន់
    - ✓ ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
- ប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុកទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការមិនឱ្យហួស**៧**ថ្ងៃ បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានបញ្ចប់។

### តួនាទី-ភារកិច្ចរបស់មន្ទីរសុខាភិបាលរាជធានី-ខេត្ត

- ជ្រើសរើសអ្នកសម្របសម្រួលមន្ទីរសុខាភិបាលខេត្តដែលនឹងត្រូវធ្វើការងារជិតស្និទ្ធជាមួយអ្នកសម្របសម្រួលដទៃទៀត និងប្រធានក្រុមចាក់វ៉ាក់សាំង
- បូកសរុបការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់ស្រុកប្រតិបត្តិនីមួយៗ
- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗ ដែលរក្សាទុកបន្ទាប់ពីទទួលពីឃ្លាំងឱសថកណ្តាល ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
- ធានាថាការិយាល័យស្រុកប្រតិបត្តិទាំងអស់មានការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈបរិក្ខារគ្រប់គ្រាន់តាមចំនួនប្រជាជនគោលដៅ
- ប្រមូលធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត
- ចុងបញ្ចប់នៃថ្ងៃនីមួយៗ មន្ទីរសុខាភិបាលរាជធានី-ខេត្តត្រូវសួរនាំការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអំពីការបំពេញការងារ (ការគ្របដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារ) និងប្រាកដថាសកម្មភាពកែតម្រូវត្រូវបានធ្វើ (បើចាំបាច់)
- ធានាថាបានរាយការណ៍ជាបន្ទាន់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
    - ✓ ហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង ព្រមទាំងការពិនិត្យព្យាបាល និង សង្គ្រោះបន្ទាន់
    - ✓ ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
- ត្រូវប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំងនិងតុល្យការស្តុក ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការ មិនឱ្យហួស **៧**ថ្ងៃ បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានបញ្ចប់។

**តួនាទី-ភារកិច្ចរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ**

- ជ្រើសរើសអ្នកសម្របសម្រួលការិយាល័យសុខាភិបាលស្រុកប្រតិបត្តិដែលត្រូវធ្វើការងារជិតស្និទ្ធជាមួយអ្នកសម្របសម្រួលខេត្តនិងប្រធានក្រុមចាក់វ៉ាក់សាំង
- ប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់កន្លែងចាក់វ៉ាក់សាំងនីមួយៗ
- បើការចុះឈ្មោះត្រូវបានធ្វើចប់សព្វគ្រប់ក្នុងតំបន់គ្របដណ្តប់របស់ខ្លួន ត្រូវធ្វើការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងដែលត្រូវការតាមចំនួនប្រជាជនគោលដៅដែលបានចុះឈ្មោះ៖
    - ✓ ប្រជាជនម្នាក់ត្រូវការវ៉ាក់សាំង ២ដូស (លើកលែងករណីពិសេស ដែលនឹងមានការណែនាំបន្ថែម) និង
    - ✓ អត្រាខាតបង់នៃវ៉ាក់សាំងកូវីដ-១៩ ១៥%
- បើការចុះឈ្មោះពុំទាន់ចប់សព្វគ្រប់ទេ ត្រូវធ្វើការប៉ាន់ប្រមាណចំនួនដូសតាមចំនួនប៉ាន់ស្មាននៃប្រជាជនគោលដៅដោយប្រើជំរឿន ឬស្ថិតិរបស់រដ្ឋបាលមូលដ្ឋាន និងដោយប្រើការសន្មតដូចខាងលើ
- គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវវ៉ាក់សាំង និង ការផ្គត់ផ្គង់ផ្សេងៗ ដែលរក្សាទុកបន្ទាប់ពីទទួលបានពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និង ក្រុមការងារចាក់វ៉ាក់សាំង
- ធានាថា រាល់កន្លែងចាក់វ៉ាក់សាំងទាំងអស់មានការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈបរិក្ខារផ្សេងៗ គ្រប់គ្រាន់ទៅតាមចំនួនប្រជាជនគោលដៅ
- ប្រមូលធនធានមនុស្ស (ក្រុមការងារចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត
- ចុងបញ្ចប់នៃថ្ងៃនីមួយៗ ត្រូវសួរនាំប្រធានក្រុមទាំងអស់ពីការបំពេញការងារ (ការគ្របដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈបរិក្ខារផ្សេងទៀត) និងប្រាកដថា សកម្មភាពកែតម្រូវត្រូវបានធ្វើ (បើចាំបាច់)
- ត្រូវប្រាកដថា ចំនួនប្រអប់សុវត្ថិភាពដែលពេញត្រូវបានប្រមូល និងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព នឹងត្រូវបានបញ្ជូនទៅកន្លែងដុត (ឡដុត >៨០០ អង្សាសេ ឬស្មើរលើវ) ដែលត្រូវបានកំណត់ចំនួន ឬបរិមាណជាគីឡូក្រាមជារៀងរាល់ថ្ងៃ
- ធានាថា បានរាយការណ៍ជាបន្ទាន់ទៅមន្ទីរសុខាភិបាលក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
    - ✓ ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងធ្ងន់ធ្ងរ និងបញ្ជូនទៅត្រួតពិនិត្យបន្តនៅមន្ទីរពេទ្យ
    - ✓ ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩និងសម្ភារៈបរិក្ខារផ្សេងទៀតក្នុងអំឡុងពេលយុទ្ធនាការ
- ត្រូវប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុកទៅមន្ទីរសុខាភិបាលមិនឱ្យហួស**៥ថ្ងៃ** បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវបានបញ្ចប់។

**តួនាទី-ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន**

- សម្របសម្រួលនីតិវិធីចុះឈ្មោះប្រជាជនគោលដៅជាមុន តាមប្រព័ន្ធអេឡិចត្រូនិច (KhmerVacc) ដែលបានណែនាំដោយក្រសួងសុខាភិបាល
- គាំទ្រដល់ការរៀបចំកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ពិសេសការរៀបចំច្រកចូល និង កន្លែងរង់ចាំ
- សម្របសម្រួលនៅកន្លែងចាក់វ៉ាក់សាំងឱ្យមានសន្តិសុខនិងសណ្តាប់ធ្នាប់ល្អ ដោយជួយរៀបចំចរន្តអ្នកមកទទួលវ៉ាក់សាំង ឱ្យរក្សាគម្លាតសង្គម និងជៀសវាងភាពកកកុញគ្នា
- ធានាសន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមការងារចាក់វ៉ាក់សាំង
- គាំទ្រនិងធានាសុវត្ថិភាពមន្ត្រីសុខាភិបាល ដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (ចាក់វ៉ាក់សាំង ការរក្សាទុកដាក់វ៉ាក់សាំង អង្កេតស្រាវជ្រាវហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង គាំទ្រផ្នែកយុត្តាធិការក្នុងករណីមានហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង...។ល។)
- គាំទ្រដល់ការប្រមូលប្រជាជនគោលដៅមកចាក់វ៉ាក់សាំង
- គាំទ្រដល់ការប្រាស្រ័យទាក់ទងពីហានិភ័យ

# ៤. ក្រុមប្រជាជនគោលដៅ

ការកំណត់ក្រុមប្រជាជនគោលដៅមានសារៈសំខាន់បំផុតសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងការសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ និងបញ្ឈប់ការរំខានដល់សង្គមនិងសេដ្ឋកិច្ច។ ក្នុងការប្រយុទ្ធនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្តេជ្ញាផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រជាពលរដ្ឋចំនួន ១០លាននាក់។

ក្នុងដំណាក់កាលដំបូង ដែលតម្រូវការវ៉ាក់សាំងមានភាពធំធេងជាសកល ហើយពិភពលោកមិនទាន់មានវ៉ាក់សាំងគ្រប់គ្រាន់នៅឡើយ ក្រុមប្រជាជនគោលដៅក្នុងដំណាក់កាលនេះ ត្រូវផ្តល់អាទិភាពទៅលើ៖

- មន្ត្រីសុខាភិបាលគ្រប់ជាន់ថ្នាក់
- កងយុទ្ធពលខេមរភូមិន្ទ និងនគរបាលជាតិ
- មន្ត្រីរាជការស៊ីវិល និងមន្ត្រីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- ជនបង្គោលសហគមន៍ និងអ្នកស្ម័គ្រចិត្ត
- ក្រុមប្រជាជនចាប់ពីអាយុ៦០ឆ្នាំឡើងទៅ
- កម្មករនិយោជិតតាមរោងចក្រ សហគ្រាស
- កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងៗទៀត (អ្នករត់ម៉ូតូឌុប រត់កង់បី កម្មករលីសែង ។ល។)
- មនុស្សពេញវ័យអាយុ ១៨-៥៩ឆ្នាំ ដែលមិនៅក្នុងក្រុមខាងលើ និង
- ជនបរទេសដែលរស់នៅ ប្រកបការងារ និងមានអាសយដ្ឋានពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

បញ្ជាក់៖ ចំពោះកុមារអាយុក្រោម១៨ឆ្នាំ មិនត្រូវបានផ្តល់ការអនុញ្ញាតឱ្យទទួលវ៉ាក់សាំងកូវីដ-១៩នាពេលនេះនៅឡើយទេ។

ក្រសួងសុខាភិបាលបានប្រកាសលើកទឹកចិត្តឱ្យប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ចុះឈ្មោះតាមប្រព័ន្ធអេឡិចត្រូនិច (KhmerVacc) ដោយខ្លួនឯង ឬដោយមានជំនួយពីអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព គណៈកម្មការទ្រទ្រង់មណ្ឌលសុខភាព សាច់ញាតិ និងមិត្តភក្តិ។ ប្រជាជនគោលដៅអាយុចាប់ពី ១៨ដល់៥៩ឆ្នាំ ដែលមានជំងឺប្រចាំកាយរ៉ាំរ៉ៃ ត្រូវបញ្ជាក់ពីស្ថានភាពជំងឺក្នុងពេលចុះឈ្មោះ ដោយគូសធីកក្នុងប្រអប់សមស្រប ដើម្បីកំណត់អាទិភាពសម្រាប់ការចាក់វ៉ាក់សាំង។

ប្រជាជនគោលដៅដែលចុះឈ្មោះរួច នឹងទទួលបានការណែនាំឱ្យទៅចាក់វ៉ាក់សាំងនៅកន្លែងចាក់វ៉ាក់សាំងដែលនៅជិតបំផុត៖

- នៅថ្នាក់កណ្តាល៖ មន្ទីរពេទ្យជាតិ មន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល និងទីកន្លែងកំណត់សមស្របផ្សេងៗទៀត ដូចជាសាលារៀនជាដើម
- នៅថ្នាក់ក្រោមជាតិ៖ មន្ទីរពេទ្យរាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងទីកន្លែងកំណត់សមស្របផ្សេងៗទៀត ដូចជាសាលារៀនជាដើម
- កងយុទ្ធពលខេមរភូមិន្ទ៖ ការចាក់វ៉ាក់សាំងនឹងធ្វើដោយមន្ត្រីសុខាភិបាលយោធា នៅមន្ទីរពេទ្យយោធា
- កងនគរបាលជាតិ៖ ការចាក់វ៉ាក់សាំងនឹងធ្វើដោយមន្ត្រីសុខាភិបាលនគរបាល នៅមន្ទីរពេទ្យនគរបាលជាតិ។

# ៥. នីតិវិធីប្រតិបត្តិ

## ៥.១. ការរៀបចំកន្លែងចាក់វ៉ាក់សាំង

កន្លែងចាក់វ៉ាក់សាំងត្រូវរៀបចំឱ្យបានសមស្របដើម្បីធានាប្រតិបត្តិការល្អ និងប្រកបដោយសុវត្ថិភាពសម្រាប់បុគ្គលិក និងប្រជាជនគោលដៅដែលមកចាក់វ៉ាក់សាំង។ ហេតុនេះ ត្រូវជ្រើសរើសទីតាំងសមស្របដែលមានខ្យល់ចេញចូលល្អ សម្រាប់រៀបចំជាទីកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ទៅតាមគោលការណ៍ណែនាំខាងក្រោមនេះ។ រូបភាពទី២ បង្ហាញពីគំនូសបំព្រួញនៃកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩គំរូ សម្រាប់បម្រើប្រជាជនគោលដៅដែលមកចាក់វ៉ាក់សាំងចំនួនប្រហែល ២០០នាក់ក្នុង១ថ្ងៃ។ ចំនួននេះអាចប្រែប្រួលទៅតាមសកម្មភាពបំពេញការងារជាក់ស្តែងនៃកន្លែងចាក់វ៉ាក់សាំងនោះ និង ការចូលរួមរបស់ប្រជាជន ក៏ដូចជាការជួយគាំទ្រពីអាជ្ញាធរពាក់ព័ន្ធ។

**<u>ទីតាំង៖</u>**

ជាទូទៅ កន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ត្រូវចែកជា៧ផ្នែកសំខាន់ៗ៖ (១)ច្រកចូល (២)ផ្នែករង់ចាំមុនចូលចាក់វ៉ាក់សាំង (៣)ផ្នែកពិគ្រោះសុខភាព (៤)ផ្នែកកត់ត្រាព័ត៌មាន (៥)ផ្នែកចាក់វ៉ាក់សាំង (៦)ផ្នែករង់ចាំក្រោយចាក់វ៉ាក់សាំង និង (៧)ផ្នែកសង្គ្រោះបន្ទាន់។ ការរៀបចំអាចបត់បែនទៅតាមទីតាំងជាក់ស្តែង ប៉ុន្តែត្រូវមាន៧ផ្នែក

និងដែលអាចអនុញ្ញាតឱ្យមានរំហូរអតិថិជនតាមលំដាប់លំដោយពីផ្នែកមួយទៅផ្នែកមួយ ដោយមិនមានបញ្ច្រាស់ទិសគ្នាឡើយ។




*រូបភាពទី២៖ គំនូសបំព្រួញកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩គំរូ សម្រាប់បម្រើក្រុមប្រជាជនគោលដៅ ចំនួនប្រហែល ២០០នាក់ ក្នុង១ថ្ងៃ*

<u>សមាសភាពក្រុមការងារ៖</u>

កន្លែងចាក់វ៉ាក់សាំងគំរូនេះ ត្រូវការក្រុមការងារមួយដែលមានមន្ត្រីចំនួន៩នាក់ និងដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានក្រុម១នាក់ មើលការខុសត្រូវរួម (ផែនការ គ្រប់គ្រង និងរបាយការណ៍) និងទទួលបន្ទុកផ្នែករង់ចាំក្រោយចាក់វ៉ាក់សាំង និងផ្នែកសង្គ្រោះបន្ទាន់។ មន្ត្រីនេះគួរជាគ្រូពេទ្យឬវេជ្ជបណ្ឌិតដែលអាចផ្តល់សេវាសង្គ្រោះបឋមបាន។ នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ប្រធានក្រុមត្រូវរាយការណ៍ពីស្ថិតិឥស្សរជន/ប្រជាជនដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ (សូមមើលទំរង់របាយការណ៍គំរូក្នុងឧបសម្ព័ន្ធ ក) និងចំនួនវ៉ាក់សាំងដែលបានទទួល និងប្រើប្រាស់ឬខូច (ដូចមានចែងក្នុងជំពូក ៥.៣) ជូនប្រធានអង្គភាពដែលគ្រប់គ្រងកន្លែងចាក់វ៉ាក់សាំងនោះ។
- អនុប្រធានក្រុម១នាក់ ទទួលបន្ទុកផ្នែកពិគ្រោះសុខភាព។ មន្ត្រីនេះ ក៏គួរជាគ្រូពេទ្យ ឬ វេជ្ជបណ្ឌិតផងដែរ
- អ្នកកត់ត្រាព័ត៌មាន២នាក់ ទទួលបន្ទុកផ្នែកកត់ត្រាព័ត៌មាន។ មន្ត្រីនេះ គួរមានជំនាញ IT ជាការប្រសើរ
- អ្នកចាក់វ៉ាក់សាំង២នាក់ ទទួលបន្ទុកផ្នែកចាក់វ៉ាក់សាំង។ មន្ត្រីនេះគួរជាគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាដែលមានជំនាញ ឬបទពិសោធន៍ចាក់វ៉ាក់សាំង

– ជំនួយការ១នាក់ ជាជំនួយការនៅផ្នែកពិគ្រោះសុខភាព។ មន្ត្រីនេះគួរជាគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា

– ជំនួយការ២នាក់ ម្នាក់ទទួលបន្ទុកនៅច្រកចូល និងម្នាក់ទៀតនៅផ្នែករង់ចាំមុនចូលចាក់វ៉ាក់សាំង

ក្រៅពីមន្ត្រីខាងលើ កន្លែងចាក់វ៉ាក់សាំងគួរមានកម្លាំងសន្តិសុខ និងអ្នកអនាម័យផងដែរ។ សន្តិសុខអាចផ្តល់ដោយអាជ្ញាធរមូលដ្ឋាន រីឯអ្នកអនាម័យ អាចជាអ្នកអនាម័យរបស់មូលដ្ឋានសុខាភិបាលដែលមានស្រាប់។

អាស្រ័យលើលទ្ធភាពធនធាន និងចំនួនប្រជាជនគោលដៅដែលមកចាក់វ៉ាក់សាំង កន្លែងចាក់វ៉ាក់សាំងគំរូដែលបានបង្ហាញខាងលើ អាចពង្រីកសមត្ថភាពរបស់ខ្លួន ដោយបន្ថែមមន្ត្រីមួយចំនួនទៅតាមការចាំបាច់។ រូបភាពទី៣ខាងក្រោមនេះ គឺជាគំនូសបំព្រួញនៃកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩មួយ ដែលអាចមានសមត្ថភាពផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ដល់ប្រជាជនគោលដៅបានប្រហែល ៣០០នាក់ ក្នុង១ថ្ងៃ ដោយបន្ថែមមន្ត្រីជំនួយការម្នាក់នៅផ្នែកពិគ្រោះសុខភាព អ្នកកត់ត្រាព័ត៌មានម្នាក់ និងអ្នកចាក់វ៉ាក់សាំងម្នាក់។ ក្នុងករណីខ្លះនៃសេណារីយោនេះ ប្រធានក្រុមអាចត្រូវការជំនួយការម្នាក់ទៀតដែលអាចជួយគាត់នៅកន្លែងរង់ចាំក្រោយចាក់វ៉ាក់សាំង និងចល័តទៅជួយផ្នែកផ្សេងទៀតនៅកន្លែងចាក់វ៉ាក់សាំងទៅតាមការចាំបាច់។




*រូបភាពទី៣៖ គំនូសបំព្រួញកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ពង្រីកសម្រាប់បម្រើក្រុមប្រជាជនគោលដៅ ចំនួនប្រហែល ៣០០នាក់ ក្នុង១ថ្ងៃ*

សម្ភារៈបរិក្ខារៈ

តារាងទី១ខាងក្រោមនេះ បង្ហាញពីសម្ភារៈបរិក្ខារដែលត្រូវការសម្រាប់ដំណើរការកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩តាមផ្នែកនីមួយៗ ដោយសញ្ញា (✓✓) បញ្ជាក់ថាជាសម្ភារៈបរិក្ខារដែលចាំបាច់បំផុតមិនអាចអត់បាន រីឯសញ្ញា (✓) បញ្ជាក់ថាជាសម្ភារៈបរិក្ខារដែលត្រូវការ តែអាចមិនចាំបាច់ៗ

***តារាងទី១៖ សម្ភារៈបរិក្ខារដែលត្រូវការសម្រាប់ដំណើរការកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩តាមផ្នែកនីមួយៗ***

| ប្រភេទសម្ភារៈបរិក្ខារ | ផ្នែកទាំង៧នៃកន្លែងចាក់វ៉ាក់សាំង | | | | | | |
|---|---|---|---|---|---|---|---|
| | (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| ឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ និងផ្ទាំងរូបភាពបង្ហាញពីការធ្វើអនាម័យដៃ | ✓ | | | | | | |
| ឧបករណ៍វាស់កំដៅ | ✓✓ | | | | | | |
| ប្រដាប់វាស់សម្ពាធឈាម | | | ✓✓ | | | | |
| អាល់កុល ឬ ជែល | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ |
| ម៉ាស់ (ម៉ាស់វះកាត់) | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ |
| របាំងការពារមុខ | ✓ | | ✓ | ✓ | ✓ | ✓ | ✓ |
| គម្របសក់ | ✓ | | ✓ | ✓ | ✓ | ✓ | ✓ |
| អាវបំពង់ | | | | | | | ✓ |
| ស្រោមដៃ (អត់ម្សៅ) | ✓ | | ✓ | ✓ | ✓✓ | | ✓✓ |
| ប្រអប់សុវត្ថិភាព | | | | | ✓✓ | | |
| ធុង/ថង់ដាក់សំណល់ឆ្លងរោគ (ធុង/ថង់ពណ៌លឿង និងស្លាកពណ៌ខ្មៅ) | | | | | ✓✓ | | |
| ធុង/ថង់ដាក់សំណល់ទូទៅ (ធុងពណ៌បៃតង ថង់ពណ៌ខ្មៅ) | | ✓ | ✓ | ✓ | ✓ | ✓ | |
| ទូរស័ព្ទដៃ (ស្មាតហ្វូនប្រភេទ Android) | | | | ✓✓ | | | |
| វ៉ាក់សាំង ធុងត្រជាក់ សឺរ៉ាំងAD សំឡីស្ងួត និង សេរ៉ូមប្រៃ | | | | | ✓✓ | | |
| កញ្ចប់ឃីតសង្គ្រោះបន្ទាន់ | | | | | | | ✓✓ |
| តុ | | | ✓✓ | ✓✓ | ✓✓ | | |
| កៅអី | | ✓✓ | ✓✓ | ✓✓ | ✓✓ | ✓✓ | |

សម្ភារៈបរិក្ខារខាងលើនេះ នឹងត្រូវផ្គត់ផ្គង់ដល់កន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ តាមប្រព័ន្ធផ្គត់ផ្គង់ដែលមានស្រាប់របស់ក្រសួងសុខាភិបាល ពិសេសសម្ភារៈបរិក្ខារវេជ្ជសាស្ត្រដូចជា វ៉ាក់សាំងកូវីដ-១៩ ធុងត្រជាក់ សឺរ៉ាំងប្រដាប់វាស់សម្ពាធឈាម សម្ភារៈដាក់សំណល់វេជ្ជសាស្ត្រ និងកញ្ចប់ឃីតសង្គ្រោះបន្ទាន់។ ក្រៅពីនេះ កន្លែងចាក់វ៉ាក់សាំងកូវីដ-១៩គួរទទួលបានការផ្គត់ផ្គង់បន្ថែមពីប្រភពផ្សេងដូចជា ក្រសួងស្ថាប័នដែលពាក់ព័ន្ធនានា សប្បុរសជន និងអាជ្ញាធរមូលដ្ឋាន សម្រាប់សម្ភារៈបរិក្ខារការពារខ្លួន (អាល់កុល ម៉ាស់ របាំងការពារមុខ គម្របសក់ អាវបំពង់) ឧបករណ៍វាស់កំដៅ តុ កៅអី ជាដើម។ ជាទូទៅ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជាអ្នកទទួលផ្គត់ផ្គង់ផ្ទាល់សម្ភារៈបរិក្ខារខាងលើដល់កន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ លើកលែងតែនៅមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្ត។

## ៥.២. ដំណើរការផ្តល់វ៉ាក់សាំង

ដំណើរការផ្តល់វ៉ាក់សាំងនៅកន្លែងចាក់វ៉ាក់សាំង ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយ ដូចបង្ហាញនៅក្នុងរូបភាពទី៤ខាងក្រោមនេះ។ រាល់សកម្មភាពនៅក្នុងផ្នែកទាំងអស់ ត្រូវរក្សាឱ្យបាននូវវិធានការអនាម័យ ការការពារខ្លួន និងការគ្រប់គ្រងសំណល់ ដូចមានចែងក្នុងចំណុច ៥.៤។




*រូបភាពទី៤៖ គំនូសបំព្រួញកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩គំរូ និង រំហូរអតិថិជន*

ដំណើរការនៃការផ្ដល់វ៉ាក់សាំងកូវីដ-១៩ដល់ប្រជាជនគោលដៅនៅកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ប្រព្រឹត្ត ទៅតាមដំណាក់កាលដូចខាងក្រោមនេះ៖

(១) **ដំណើរការនៅច្រកចូល**

ជំនួយការនៅទីនេះត្រូវ៖

- អញ្ជើញអ្នកមកចាក់វ៉ាក់សាំងឱ្យចូលតាមគន្លងខ្សែដែលបានកំណត់ ដោយរក្សាគម្លាត ១,៥ ម៉ែត្រ
- ត្រួតពិនិត្យកំដៅ បាញ់អាល់កុលដៃ និង ធានាថាគាត់មានពាក់ម៉ាស់ត្រឹមត្រូវ (បើពាក់មិនត្រឹមត្រូវ ដូចជាចំហរទ្រមុះ ឬដោះម៉ាស់ពេលនិយាយគ្នា) សូមណែនាំគាត់ពាក់ឱ្យបានត្រឹមត្រូវ។ តែបើគាត់គ្មានម៉ាស់ ត្រូវផ្ដល់ម៉ាស់ជូនគាត់)។ ជាការប្រសើរ ត្រូវអញ្ជើញគាត់ឱ្យលាងដៃជាមួយទឹក និងសាប៊ូមុននឹងចូលទៅកន្លែងរង់ចាំ (ប្រសិនបើមានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃនៅក្បែរច្រកចូល)
- ចំពោះអ្នកមានកំដៅខ្ពស់ចាប់ពី ៣៧,៥ អង្សាសេឡើង ឬ មានរោគសញ្ញាសង្ស័យដទៃទៀតនៃជំងឺកូវីដ-១៩ (ក្អក ហត់...) ត្រូវចាត់វិធានការតាមការណែនាំស្ដីពីករណីសង្ស័យមានជំងឺកូវីដ-១៩
- ចំពោះអ្នកដែលមិនមានសញ្ញាសង្ស័យដូចខាងលើ អញ្ជើញគាត់ឱ្យទៅអង្គុយនៅកន្លែងរង់ចាំ

(២) **ដំណើរការនៅផ្នែករង់ចាំមុនចូលចាក់វ៉ាក់សាំង៖**

ជំនួយការនៅទីនេះត្រូវ៖

- រៀបចំឱ្យអ្នកមកចាក់វ៉ាក់សាំងអង្គុយលើកៅអីដែលមានរក្សាគម្លាត ១,៥ ម៉ែត្រ
- ផ្ទៀងផ្ទាត់ឈ្មោះ និងអាយុទៅតាមបញ្ជីក្រុមគោលដៅដែលបានរៀបចំដោយអាជ្ញាធរមូលដ្ឋាន ឬអង្គភាពសម្របសម្រួលដែលពាក់ព័ន្ធ
- ផ្ដល់លិខិតព្រមព្រៀងចាក់វ៉ាក់សាំងកូវីដ-១៩ជូនអតិថិជន ដែលកំពុងរង់ចាំដើម្បីអាននិងបំពេញ (ដោយមានការពន្យល់និងណែនាំបើចាំបាច់)
- ផ្ដល់លេខរៀងចូល (ត្រូវមាន២ប្រភេទ៖ អ្នកចាក់លើកទី១ និងទី២ បើមានផ្ដល់សេវាចាក់លើកទី២ដែរ)
- ហៅអតិថិជនតាមលេខរៀង ឱ្យចូលទៅផ្នែកពិគ្រោះសុខភាព ម្ដងមួយៗ និង ជៀសវាងភាពកកកុញ

(៣) **ដំណើរការនៅផ្នែកពិគ្រោះសុខភាព៖**

- គ្រូពេទ្យទទួលបន្ទុកពិគ្រោះសុខភាព ត្រូវសួរប្រវត្តិជំងឺ និងពិនិត្យសុខភាព (ទៅតាមករណីអ្នកមកចាក់លើកទី១ និងទី២) រួចធ្វើសេចក្ដីសម្រេចចិត្តថាតើ អតិថិជននោះគាត់អាចចាក់វ៉ាក់សាំងបានដែរឬទេ ដោយផ្អែកលើគោលការណ៍បច្ចេកទេសដែលបានណែនាំនៅពេលបណ្ដុះបណ្ដាល និងឯកសារជំនួយស្មារតីសម្រាប់គ្រូពេទ្យពិគ្រោះការចាក់វ៉ាក់សាំងកូវីដ-១៩ សម្រាប់ប្រភេទវ៉ាក់សាំងកូវីដ-១៩នីមួយៗ

- ក្នុងករណីចាំបាច់ គ្រូពេទ្យណែនាំឱ្យគិលានុប្បដ្ឋាក/គិលានុប្បដ្ឋាយិកាជាជំនួយការវាស់សម្ពាធឈាម និងយកសញ្ញាជីវិត ឬឱ្យគាត់សម្រាកដើម្បីតាមដានមួយរយៈមុននឹងធ្វើសេចក្ដីសម្រេចចិត្ត
- ចំពោះអ្នកមិនអាចចាក់វ៉ាក់សាំងបាន (ក្រោយពីពិគ្រោះសុខភាពហើយ) ចូរពន្យល់ និងអនុញ្ញាតឱ្យគាត់ត្រឡប់ទៅវិញ (ក្រោយចុះហត្ថលេខាឬផ្ដិតមេដៃលើលិខិតព្រមព្រៀងចាក់វ៉ាក់សាំងកូវីដ-១៩) ដោយមានការបញ្ជាក់ពីលទ្ធភាពដែលគាត់អាចមកចាក់លើកក្រោយទៀតដែរ ឬអត់ (ហាមចាក់ដាច់ខាត ឬបណ្ដោះអាសន្ន)
- ចំពោះអ្នកអាចចាក់បាន ចូរពន្យល់គាត់ និងសុំការយល់ព្រមចាក់វ៉ាក់សាំងពីគាត់ ដោយឱ្យគាត់ចុះហត្ថលេខាឬផ្ដិតមេដៃលើលិខិតព្រមព្រៀងចាក់វ៉ាក់សាំងកូវីដ-១៩ រួចអញ្ជើញគាត់ឱ្យទៅកាន់ផ្នែកកត់ត្រាព័ត៌មាន។ តែបើគាត់ស្ទាក់ស្ទើរ ពន្យល់គាត់បន្ថែម។ បើក្រោយពីពន្យល់ហើយ គាត់មិនព្រមចាក់ សូមឱ្យគាត់គូសយកពាក្យថា 'មិនព្រមចាក់វ៉ាក់សាំង' ព្រមទាំងចុះហត្ថលេខាឬផ្ដិតមេដៃលើលិខិតព្រមព្រៀងចាក់វ៉ាក់សាំង រួចអាចឱ្យគាត់ត្រឡប់ទៅវិញបាន។ សូមបញ្ជាក់ថា ចំពោះអ្នកមកចាក់លើកទី២ មិនតម្រូវឱ្យចុះហត្ថលេខាឬផ្ដិតមេដៃលើលិខិតព្រមព្រៀងចាក់វ៉ាក់សាំងកូវីដ-១៩ ទៀតទេ។

(៤) <u>ដំណើរការនៅផ្នែកកត់ត្រាព័ត៌មាន៖</u>

អ្នកកត់ត្រាព័ត៌មានត្រូវ៖



- បំពេញព័ត៌មានចាំបាច់របស់អ្នកមកទទួលវ៉ាក់សាំងក្នុងប្រព័ន្ធចុះឈ្មោះអេឡិចត្រូនិច (KhmerVacc) ទៅតាមអ្នកមកចាក់លើកទី១ ឬលើកទី២ (បើចាំបាច់)។ ជាទូទៅ អ្នកមកទទួលវ៉ាក់សាំងបានចុះឈ្មោះក្នុងប្រព័ន្ធអេឡិចត្រូនិចរួចហើយ។
- សម្រាប់អ្នកដែលបានចុះឈ្មោះក្នុងប្រព័ន្ធអេឡិចត្រូនិចរួចហើយ មន្ត្រីកត់ត្រាព័ត៌មានត្រូវឆែកក្នុងប្រព័ន្ធ (ដោយប្រើអត្តសញ្ញាណរបស់អតិថិជន ដូចជាលេខទូរស័ព្ទ) ដើម្បីធានាថា គាត់ពិតជាបានចុះឈ្មោះ និង បំពេញព័ត៌មានគ្រប់គ្រាន់ ដោយមានបញ្ចូលរូបថតផង
- ក្នុងករណីមិនទាន់បានចុះឈ្មោះក្នុងប្រព័ន្ធ មន្ត្រីកត់ត្រាព័ត៌មានត្រូវ ជួយចុះឈ្មោះគាត់ក្នុងប្រព័ន្ធ និង ថតរូបរបស់គាត់ទុកក្នុងទូរស័ព្ទដៃ (ដើម្បីសម្រួលការងារឱ្យបានលឿន កិច្ចការនេះអាចត្រូវបានធ្វើមុនពេលមកចាក់វ៉ាក់សាំង ឬនៅកន្លែងរង់ចាំ ដោយមានជំនួយពីក្រុមគ្រួសារ មិត្តភក្តិ ឬអាជ្ញាធរមូលដ្ឋាន)។
- បំពេញព័ត៌មានលើបណ្ណចាក់វ៉ាក់សាំង រួចប្រគល់ឱ្យអតិថិជន។ តែមុននឹងផ្ដល់បណ្ណ ត្រូវផ្ទៀងផ្ទាត់ថា ព័ត៌មានក្នុងបណ្ណត្រូវបានភ្ជាប់នឹងប្រព័ន្ធអនឡាញ (Activated)
- អញ្ជើញគាត់ឱ្យទៅកាន់ផ្នែកចាក់វ៉ាក់សាំង

**(៥) ដំណើរការនៅផ្នែកចាក់វ៉ាក់សាំង៖**

អ្នកចាក់វ៉ាក់សាំងត្រូវ៖

- រៀបចំចាក់វ៉ាក់សាំងកូវីដ-១៩ជូនអតិថិជន (ទៅតាមប្រភេទវ៉ាក់សាំង សម្រាប់អ្នកចាក់លើកទី១ និងទី២ ក្នុងករណីមានការទទួលចាក់វ៉ាក់សាំងក្នុងកន្លែងតែមួយ សម្រាប់អ្នកចាក់លើកទី១ និងទី២) ទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ (ដើម្បីជៀសវាងការចាក់ច្រឡំរវាងអ្នកមកចាក់លើកទី១ និងទី២ មុននឹងចាក់ អ្នកចាក់ត្រូវពិនិត្យបណ្ណចាក់វ៉ាក់សាំងឱ្យបានច្បាស់ជាមុនសិន)
- បំពេញព័ត៌មានចាំបាច់លើបញ្ជីកត់ត្រា (បើចាំបាច់)
- អញ្ជើញគាត់ឱ្យទៅកន្លែងរង់ចាំក្រោយចាក់វ៉ាក់សាំង

អ្នកចាក់វ៉ាក់សាំងត្រូវប្រាកដថា ការជ្រើសរើសកម្រិតដូស របៀបចាក់ និងកន្លែងចាក់ត្រឹមត្រូវតាមការណែនាំសម្រាប់វ៉ាក់សាំងកូវីដ-១៩ដូចខាងក្រោមនេះ៖

**កម្រិតដូស៖**

សម្រាប់វ៉ាក់សាំងភាគច្រើនដែលចរាចរលើទីផ្សារ ឬ កំពុងត្រូវបានផលិត ត្រូវចាក់២ដូស។ ក្នុងករណីនេះ ការចាក់ទាំង២ដូសលើបុគ្គលម្នាក់ ត្រូវតែប្រើផលិតផលវ៉ាក់សាំងតែមួយ។

***តារាងទី២៖ ប្រភេទវ៉ាក់សាំងកូវីដ-១៩ដែលកំពុងប្រើនៅព្រះរាជាណាចក្រកម្ពុជា***

| វ៉ាក់សាំងកូវីដ-១៩ | សីតុណ្ហភាពរក្សាទុក | ចំណុះ/១ដូស | កន្លែងចាក់ | គម្លាតដូសទី១ ទៅដូសទី២ |
|---|---|---|---|---|
| SinoPharm (Beijing ) | ពី +២ ទៅ +៨ អង្សាសេ | ០,៥ ម.ល | ចាក់សាច់ដុំដែលតូអ៊ីត នៅដើមដៃស្តាំ | ២១ * ទៅ ២៨ ថ្ងៃ |
| SinoVac (Biotech Ltd) | ពី +២ ទៅ +៨ អង្សាសេ | ០,៥ ម.ល | ចាក់សាច់ដុំដែលតូអ៊ីត នៅដើមដៃស្តាំ | ២១ * ទៅ ២៨ ថ្ងៃ |
| AstraZeneca (SII) | ពី +២ ទៅ +៨ អង្សាសេ | ០,៥ ម.ល | ចាក់សាច់ដុំដែលតូអ៊ីត នៅដើមដៃស្តាំ | ៨ ទៅ ១២ សប្តាហ៍ |

** កំណត់សំគាល់៖ នៅក្នុងស្ថានភាពដែលមានការរាតត្បាតនៃជំងឺកូវីដ-១៩ខ្លាំងក្នុងសហគមន៍ ដែលតម្រូវឱ្យមានការចាក់វ៉ាក់សាំងបន្ទាន់ដល់ប្រជាជនគោលដៅ រយៈពេលគម្លាតពីការចាក់ដូសទី១ ទៅដូសទី២ នៃវ៉ាក់សាំង Sinopharm និង Sinovac អាចបង្រួមមកនៅត្រឹមតែ ១៤ថ្ងៃ។*

របៀបចាក់៖

ចាក់សាច់ដុំដែលតូអ៊ីត នៅដើមដៃស្តាំ (មើលរូបណែនាំ)



✓ ប្រើប្រាស់សឺរ៉ាំងប្រភេទ ០,៥ មល អេឌី (AD)។ សឺរ៉ាំងប្រភេទអេឌីនេះមានយន្តការសុវត្ថិភាពផ្នែកខាងក្នុង ដែលធានាថាវាអាចប្រើប្រាស់បានតែម្តង និងមិនអាចប្រើប្រាស់បានជាលើកទី២ទេ។




✓ ជូតសម្អាតស្បែកនៅកន្លែងដែលត្រូវចាក់ដោយប្រើសំឡីនិងទឹកក្តៅឧណ្ហៗ ឬសេរ៉ូមប្រៃ (ជៀសវាងជូតដោយសំឡីអាល់កុល)។

✓ កាន់ដងសឺរ៉ាំងដោយម្រាមចង្អុលដៃនិងមេដៃ ដោយតម្រង់មុខម្ជុលឡើងលើ។ ដៃម្ខាងទៀតចាប់សាច់ដុំដើមដៃថ្នមៗ រួចចាក់ម្ជុលចូលត្រង់ ក្នុងទិសដៅ ៩០ដឺក្រេ ទៅក្នុងសាច់ដុំ រួចសង្កត់ពីស្តុងសឺរ៉ាំង តែមិនត្រូវរុញបន្ថែមម្ជុលដែលបានចាក់ទៅក្នុងសាច់ដុំហើយទេ។ ដកម្ជុលចេញរហ័ស តែថ្នមៗ តាមទិសដៅដែលចាក់ម្ជុលចូល រួចចោលម្ជុលនិងសឺរ៉ាំងក្នុងប្រអប់សុវត្ថិភាពភ្លាម ដោយ***មិនត្រូវព្យាយាមគ្របម្ជុលវិញទេ***។




**(៦ & ៧) __ដំណើរការនៅផ្នែករង់ចាំក្រោយចាក់វ៉ាក់សាំង និងផ្នែកសង្គ្រោះបន្ទាន់__៖**

គ្រូពេទ្យដែលជាប្រធានក្រុមទទួលបន្ទុកនៅទីនេះត្រូវ៖

- ធានាថា អ្នកដែលបានចាក់វ៉ាក់សាំងកូវីដ-១៩រួច ត្រូវនៅកន្លែងរង់ចាំក្រោយចាក់នេះរយៈពេល យ៉ាងតិច៣០នាទីដើម្បីតាមដានក្រែងមានផលរំខានផ្សេងៗក្រោយចាក់ ពិសេសប្រតិកម្មធ្ងន់ធ្ងរដែលមិនអាចស្មានដឹងជាមុន
- ក្រោយរង់ចាំ៣០នាទីហើយ ចំពោះអ្នកដែលមិនមានបញ្ហាអ្វីកើតឡើងទេ អាចអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ។ ក្នុងករណីសង្ស័យ ត្រូវតាមដានបន្តមួយរយៈ (អាច ១-២ម៉ោង ទៅតាមស្ថានភាពជាក់ស្តែង)
- ប្រាប់ពេលវេលាដែលត្រូវមកចាក់លើកទី២ (ចំពោះអ្នកចាក់លើកទី១)
- សូមណែនាំពីផលរំខាន និងវិធានការនៅពេលមានផលរំខានដែលអាចកើតមានជាយថាហេតុនៅក្រោយពេលត្រឡប់ទៅផ្ទះវិញ
- ក្នុងករណីមានប្រតិកម្មធ្ងន់ធ្ងរដោយចៃដន្យ ត្រូវធ្វើការសង្គ្រោះបឋម មុននឹងបញ្ជូនទៅកាន់កន្លែងសង្គ្រោះបន្ទាន់ដែលនៅជិតបំផុត

## ៥.៣. ការគ្រប់គ្រងប្រព័ន្ធត្រជាក់ និងវ៉ាក់សាំង

ប្រទេសកម្ពុជាមានប្រព័ន្ធផ្គត់ផ្គង់រឹងមាំសម្រាប់ការងារផ្តល់ថ្នាំបង្ការជាប្រចាំ រួមទាំងបទពិសោធន៍ក្នុងការគ្រប់គ្រងយុទ្ធនាការផ្តល់ថ្នាំបង្ការ តាំងពីការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើងមកម្ល៉េះ ដែលផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។

<u>**គន្លឹះសំខាន់ៗអំពីសមត្ថភាពស្តុកទុកវ៉ាក់សាំងកូវីដ-១៩៖**</u>

- ជាទូទៅ មូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់មានសមត្ថភាពរក្សាទុកវ៉ាក់សាំងបានល្អប្រសើរ ដែលអាចទទួលបន្ថែមនូវវ៉ាក់សាំងកូវីដ-១៩បាន។ បើមានបញ្ហា ត្រូវរាយការណ៍ជូនថ្នាក់លើ (ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសម្រាប់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកស្រុក និងមន្ទីរសុខាភិបាលខេត្តសម្រាប់មន្ទីរពេទ្យខេត្ត) និងរកដំណោះស្រាយបន្ទាន់ភ្លាមៗ
- បរិមាណវ៉ាក់សាំងដែលត្រូវបានបែងចែកសម្រាប់កន្លែងចាក់វ៉ាក់សាំងនីមួយៗនឹងអាស្រ័យជាចម្បងលើទិន្នន័យនៃសម្រង់ប្រជាជនគោលដៅ និងកាលវិភាគនៃការចាក់វ៉ាក់សាំងដូចក្នុងផែនការលម្អិត
- សម្ភារៈបរិក្ខារដូចជា សឺរ៉ាំង និងប្រអប់សុវត្ថិភាពនឹងត្រូវបានបែងចែកជាមួយវ៉ាក់សាំង ព្រមទាំងបណ្ណចាក់វ៉ាក់សាំង)
- វ៉ាក់សាំងកូវីដ-១៩ គួរត្រូវបានរក្សាទុក និង ដឹកជញ្ជូនក្នុងសីតុណ្ហភាពសមស្រប ចន្លោះ +២ ទៅ +៨ អង្សាសេ
- ធុងវ៉ាក់សាំង និងប្រអប់ត្រជាក់ដែលត្រូវការសម្រាប់យុទ្ធនាការគួរត្រូវបានគណនាបរិមាណ និងរៀបចំទុកជាមុន
- ធ្វើការពិនិត្យប្រអប់ត្រជាក់ (រកមើលលេច ឬ របូតធ្នក) និងជ្រើសរើសយកតែប្រអប់ត្រជាក់ណាដែលល្អមកប្រើ
- បើវ៉ាក់សាំងកូវីដ-១៩ ជាវត្ថុរាវ **មិនត្រូវឱ្យវាកកទេ** ព្រោះអាចធ្វើឱ្យបាត់ប្រសិទ្ធភាពរបស់វ៉ាក់សាំង ហើយវាមិនអាចការពារប្រឆាំងនឹងជំងឺកូវីដ-១៩បានទេ។

<u>**របាយការណ៍វ៉ាក់សាំង និងសម្ភារៈដែលត្រូវការ៖**</u>

- ប្រធានក្រុមចាក់វ៉ាក់សាំងកូវីដ-១៩ របស់មូលដ្ឋានសុខាភិបាលត្រូវរៀបចំរបាយការណ៍ស្តីពីការផ្គត់ផ្គង់ (វ៉ាក់សាំង និងភ័ស្តុភារ) ឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ
- របាយការណ៍វ៉ាក់សាំង និងភ័ស្តុភារនេះគួរត្រូវបានផ្ញើពីកន្លែងចាក់វ៉ាក់សាំង ទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ជារៀងរាល់ថ្ងៃ បន្ទាប់ពីបានបញ្ចប់ការចាក់វ៉ាក់សាំងនៃថ្ងៃនីមួយៗ
- ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនឹងពិនិត្យរបាយការណ៍ រួចបញ្ជូនទៅមន្ទីរសុខាភិបាលខេត្តក្នុងថ្ងៃដដែល
- មន្ទីរសុខាភិបាលខេត្តពិនិត្យ និងសរុបរបាយការណ៍ស្រុករួចផ្ញើទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងថ្ងៃដដែល។



៥៥

## ៥.៤. វិធានការអនាម័យ ការការពារខ្លួន និងការគ្រប់គ្រងសំណល់

ដើម្បីបង្ការការចម្លងជំងឺកូវីដ-១៩ ដល់មន្ត្រីផ្តល់សេវា និងប្រជាពលរដ្ឋដែលមកចាក់វ៉ាក់សាំងនៅកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ក្រុមការងារនៅកន្លែងចាក់វ៉ាក់សាំងទាំងអស់ត្រូវគោរពគោលការណ៍អនាម័យ ការការពារខ្លួន និងការគ្រប់គ្រងសំណល់ឱ្យបានល្អតាមការណែនាំនេះ។

<u>ទំរង់ការធ្វើអនាម័យដៃ៖</u>

- រៀបចំកន្លែងធ្វើអនាម័យដៃ (ដោយទឹកនិងសាប៊ូ ឬដោយអាល់កុល) នៅផ្លូវចូល និងនៅផ្លូវចេញ
- សមាជិកក្រុមការងារត្រូវធ្វើអនាម័យដៃតាមគោលការណ៍ មុន ២ (១.មុនប៉ះអ្នកជំងឺ ២.មុនធ្វើទំរង់ការ) និងក្រោយ ៣ (១.ក្រោយប៉ះអ្នកជំងឺ ២.ក្រោយប៉ះប្រឡាក់សារធាតុរាវអ្នកជំងឺ ៣.ក្រោយប៉ះពាល់សម្ភារៈអ្នកជំងឺ
- ប្រជាពលរដ្ឋត្រូវធ្វើអនាម័យដៃមុនពេលចូលកន្លែងចាក់វ៉ាក់សាំង និងពេលចេញពីកន្លែងចាក់វ៉ាក់សាំង
- សមាជិកក្រុមការងារចាក់វ៉ាក់សាំង ត្រូវធ្វើអនាម័យដៃមុនពេលពាក់ និងដោះឧបករណ៍ការពារខ្លួន និងមុនពាក់ស្រោមដៃផងដែរ




<u>ទំរង់ការប្រើឧបករណ៍ការពារខ្លួន</u>

ការប្រើសម្ភារៈនិងឧបករណ៍ការពារខ្លួនត្រូវអនុឡោមទៅតាមកម្រិតនៃការប្រឈមនឹងការឆ្លង។ រូបភាពទី៥ ខាងក្រោមនេះបង្ហាញពីសម្ភារៈនិងឧបករណ៍ការពារខ្លួនដែលត្រូវប្រើតាមប្រភេទនីមួយៗ និងសមាជិកក្រុមការងារផ្តល់សេវាចាក់វ៉ាក់សាំងតាមផ្នែកនីមួយៗ ដោយមានសញ្ញា (✓) បញ្ជាក់ថាត្រូវប្រើ។ ក្នុងស្ថានភាពដែលមានការប្រឈមនឹងការឆ្លងខ្លាំង សមាជិកក្រុមការងារចាក់វ៉ាក់សាំងគ្រប់ផ្នែក (គិតទាំងផ្នែកដែលមិនមានសញ្ញា (✓) បញ្ជាក់ថាត្រូវប្រើផងដែរ) អាចប្រើសម្ភារៈនិងឧបករណ៍ការពារខ្លួនទាំងអស់ក្នុងរូបភាពទី៥ខាងក្រោមនេះបាន។

| លរ | មន្ត្រីបម្រើការតាមផ្នែកនៅកន្លែងចាក់វ៉ាក់សាំង | លាងដៃ  | ម៉ាស់ពេទ្យ  | គម្របសក់  | របាំងមុខ  | ស្រោមដៃ  | អាវបំពាក់  |
|---|---|---|---|---|---|---|---|
| ១ | ជំនួយការនៅច្រកចូល | ✓ | ✓ | ✓ | ✓ | ✓ | |
| ២ | ជំនួយការនៅផ្នែករង់ចាំ | ✓ | ✓ | | | | |
| ៣ | ជំនួយការគ្រូពេទ្យពិគ្រោះសុខភាព | ✓ | ✓ | ✓ | ✓ | អាចប្រើបាន | |
| ៤ | គ្រូពេទ្យពិគ្រោះសុខភាព | ✓ | ✓ | ✓ | ✓ | អាចប្រើបាន | |
| ៥ | អ្នកកត់ត្រាព័ត៌មាន | ✓ | ✓ | ✓ | ✓ | ✓ | |
| ៦ | អ្នកចាក់វ៉ាក់សាំង | ✓ | ✓ | ✓ | ✓ | ✓ | |
| ៧ | អ្នកសង្គ្រោះបឋម | ✓ | ✓ | ✓ | ✓ | ប្រើពេលសង្គ្រោះ | ប្រើពេលសង្គ្រោះ |

*រូបភាពទី៥៖ សម្ភារៈ និងឧបករណ៍ការពារខ្លួនដែលត្រូវប្រើតាមប្រភេទនីមួយៗ និង សមាជិកក្រុមការងារម្នាក់ៗ*

<u>ការគ្រប់គ្រងសំណល់នៅកន្លែងចាក់វ៉ាក់សាំង</u>










- សម្លាប់មេរោគនៅទីកន្លែងចាក់វ៉ាក់សាំងដោយប្រើអូហ្សាវ៉ែល (០,០៥%) ជូតសម្អាត ជាពិសេសកន្លែងដែលប្រជាពលរដ្ឋប៉ះពាល់ច្រើនជាងគេ
- ត្រូវមានសម្ភារៈបរិក្ខារចាំបាច់សម្រាប់គ្រប់គ្រងសំណល់នៅកន្លែងចាក់វ៉ាក់សាំង៖
  - ✓ ប្រអប់សុវត្ថិភាពសម្រាប់ដាក់សឺរ៉ាំងដែលប្រើរួច
  - ✓ ធុងនិងថង់ពណ៌លឿងស្លាកខ្មៅសម្រាប់ដាក់សំណល់ឆ្លងរោគ (ស្រោមដៃ ម៉ាស់វះកាត់ប្រើរួច សំឡីចាក់ថ្នាំ...)
  - ✓ ធុងពណ៌បៃតងនិងថង់ពណ៌ខ្មៅសម្រាប់សំណល់ទូទៅ (សំបកដបវ៉ាក់សាំង ក្រដាស ប្លាស្ទិច សំណល់អាហារ...)
- ត្រូវធានាថា ម្ជុលសឺរ៉ាំងដែលចាក់រួច និងសំណល់ឆ្លងរោគដទៃទៀតត្រូវបានទុកដាក់ក្នុងធុង/ថង់ត្រឹមត្រូវ (ដោយមិនឱ្យពេញលើសពី៣/៤ឡើយ) និង ប្រមូលយកទៅកំទេចចោលត្រឹមត្រូវតាមប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដែលមានស្រាប់នៅតាមមូលដ្ឋានសុខាភិបាល។ បើកន្លែងចាក់វ៉ាក់សាំងមិនស្ថិតនៅក្នុងមូលដ្ឋានសុខាភិបាល ស្រុកប្រតិបត្តិ ឬ មន្ទីរសុខាភិបាលដែលជាប់ពាក់ព័ន្ធជាអ្នកទទួលខុសត្រូវ។

<u>សុវត្ថិភាពនៃការចាក់វ៉ាក់សាំង</u>

- ធ្វើអនាម័យដៃមុនពេលរៀបចំវ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋម្នាក់ៗ (តែហាមដាច់ខាតយកអាល់កុលជូតលើក្បាលដប)
- ចោលសឺរ៉ាំងចាក់រួចទៅក្នុងប្រអប់សុវត្ថិភាព
- ប្រអប់សុវត្ថិភាពដាក់សឺរ៉ាំងតែត្រឹម ៣/៤
- បន្ទាប់ពីដាក់ត្រឹម៣/៤ ត្រូវបិទមាត់ឱ្យជិត និងហាមបើកបន្ទាប់ពីបិទរួច

## ៥.៥. ការពិនិត្យ តាមដាន និងគ្រប់គ្រងហេតុការណ៍កើតមានក្រោយចាក់វ៉ាក់សាំង

- វ៉ាក់សាំងកូវីដ-១៩របស់កម្មវិធីជាតិ ក៏ដូចជាវ៉ាក់សាំងដទៃទៀតដែរ ជាទូទៅមានសុវត្ថិភាព និងមិនបណ្តាលឱ្យមានផលរំខានអ្វីទេ។ តែក្នុងករណីខ្លះ វាអាចបណ្តាលឱ្យមានផលរំខាន ឬ ប្រតិកម្មមួយចំនួនដែលអាចលេចចេញភ្លាមៗបន្ទាប់ពីការចាក់ ឬក្នុងអំឡុងពេល២ឬ៣ថ្ងៃក្រោយបន្ទាប់ពីការចាក់រួច។
- ហេតុការណ៍ដែលកើតមានក្រោយចាក់វ៉ាក់សាំង (AEFI) គឺជាហេតុការណ៍វេជ្ជសាស្ត្រណាមួយដែលកើតឡើងបន្ទាប់ពីការចាក់វ៉ាក់សាំង ដែលមិនប្រាកដថាបណ្តាលមកពីការប្រើប្រាស់វ៉ាក់សាំងទេ។ ហេតុការណ៍នេះអាចជាសញ្ញាមួយដែលកើតឡើងដោយចេតនា ឬ អចេតនាណាមួយដែលអាចបញ្ជាក់បានច្បាស់លាស់តាមរយៈមន្ទីរពិសោធន៍ ឬជាការស្តែងចេញជាជំងឺតែម្តង ដែលចែកចេញជា៥ក្រុមដូចមានបង្ហាញក្នុងរូបភាពទី៦)

| ១ | ២ | ៣ | ៤ | ៥ |
| --- | --- | --- | --- | --- |
| ប្រតិកម្មទាក់ទងនឹងផលិតផលវ៉ាក់សាំង Vaccine product-related reaction | ប្រតិកម្មទាក់ទងនឹងគុណភាពវ៉ាក់សាំងមិនល្អ Vaccine quality defect-related reaction | ប្រតិកម្មទាក់ទងនឹងកំហុសក្នុងការផ្តល់ថ្នាំបង្ការ Immunization error-related reaction | ប្រតិកម្មទាក់ទងនឹងថប់បារម្ភពេលទទួលថ្នាំបង្ការ Immunization anxiety-related reaction | ហេតុការណ៍ចៃដន្យ-ជាន់ដាន Coincidental event |
| ឧទាហរណ៍ ហើមតឹងអវៈយវៈបន្ទាប់ពីចាក់ DTP | ឧទាហរណ៍ បរាជ័យនៃអ្នកផលិតក្នុងការបង្អន់ធ្វើឱ្យអកម្មទាំងស្រុងវ៉ាក់សាំងប៉ូល្យ៉ូដែលបង្កើតពីវីរុសប៉ូល្យ៉ូដែលនាំដល់ការលេចចេញនូវករណីខ្វិនដោយប៉ូល្យ៉ូ | ឧទាហរណ៍ ការចម្លងរោគតាមរយៈដបវ៉ាក់សាំងដែលមានច្រើនដូសដែលប្រើប្រាស់មិនបានត្រឹមត្រូវ (ការអនុវត្តខ្វះអនាម័យ) | ឧទាហរណ៍ ខ្យល់គរនៅលើកុមារជំទង់ បន្ទាប់ពីការទទួលថ្នាំបង្ការ (Vasovagal syncope) | ឧទាហរណ៍ គ្រុនក្តៅកើតមានក្រោយពីការទទួលថ្នាំបង្ការ (ទំនាក់ទំនងជាបណ្តោះអាសន្ន) តែការពិតបណ្តាលមកពីជំងឺគ្រុនចាញ់ |

*រូបភាពទី៦៖ ប្រភេទទាំង៥នៃហេតុការណ៍ដែលអាចកើតមានក្រោយការចាក់វ៉ាក់សាំង*

ការពិនិត្យ តាមដាន និង គ្រប់គ្រងហេតុការណ៍កើតឡើងក្រោយការចាក់វ៉ាក់សាំង ត្រូវធ្វើឡើង តាមរចនា សម្ព័ន្ធមានស្រាប់ដែលបានបង្កើតឡើងដោយគណៈកម្មាធិការប្រឹក្សាជំនាញសុវត្ថិភាពឱសថ ដូចក្នុងរូបភាពទី៧។

- ក្រុមចាក់វ៉ាក់សាំងនីមួយៗ ត្រូវមានកញ្ចប់ឃីតសង្គ្រោះបន្ទាន់ និងរក្សាវាជាប់ខ្លួនក្នុងអំឡុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។ បើមានហេតុការណ៍ធ្ងន់ធ្ងរដូចជា ប្រតិកម្មអាណាហ្វីឡាក់ស៊ី ក្រោយការចាក់វ៉ាក់សាំង ប្រធានក្រុមត្រូវធ្វើការសង្គ្រោះបឋម រួចបញ្ជូនអ្នករងគ្រោះជាបន្ទាន់ទៅផ្នែកសង្គ្រោះបន្ទាន់នៅតាមមន្ទីរពេទ្យដែលនៅជិតបំផុត និងត្រូវរាយការណ៍ទៅអ្នកសម្របសម្រួលខេត្ត។ សូមមើល ឧបសម្ព័ន្ធ ខ សម្រាប់សម្ភារៈបរិក្ខារដែលចាំបាច់ត្រូវមាននៅក្នុងកញ្ចប់ឃីត។
- រដ្ឋបាលមូលដ្ឋាន មេភូមិ អ្នកស្ម័គ្រចិត្ត ត្រូវរាយការណ៍ទៅមណ្ឌលសុខភាព នូវរាល់ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង ដែលកើតឡើងបន្ទាប់ពីប្រជាពលរដ្ឋដែលចាក់វ៉ាក់សាំងរួច ត្រលប់ទៅផ្ទះវិញ។ មណ្ឌលសុខភាពនឹងរាយការណ៍ជាបន្តទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងសម្របសម្រួលការបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ។
- ហេតុការណ៍ដែលត្រូវរាយការណ៍ និងយកចិត្តទុកដាក់៖
  - ✓ ប្រតិកម្មវ៉ាក់សាំង (Anaphylaxis)
  - ✓ ខូចខាតបេះដូង និងប្រព័ន្ធសរសៃឈាមស្រួចស្រាវ (Acute cardiovascular injury)
  - ✓ ខូចខាតតម្រងនោមស្រួចស្រាវ (Acute kidney injury)
  - ✓ ចង្កោមរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (Acute respiratory distress syndrome)
  - ✓ ខូចខាតថ្លើមស្រួចស្រាវ (Acute liver injury)
  - ✓ រលាកខួរក្បាលនិងខួរឆ្អឹងខ្នងទាំងមូលស្រួចស្រាវ (Acute disseminated encephalomyelitis)
  - ✓ បង្កើនសភាពធ្ងន់ធ្ងរនៃជំងឺមានស្រាប់ក្រោយពីចាក់វ៉ាក់សាំង (Enhanced disease following immunization)
  - ✓ ប្រកាច់ (Generalized convulsions)
  - ✓ កង្វះគ្រាប់ឈាមប្លាកែត (Thrombocytopenia)
- មន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិត្រូវសម្របសម្រួលជិតស្និទ្ធ ដោយចេញកំណត់ហេតុទៅមន្ទីរពេទ្យខេត្ត មន្ទីរពេទ្យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ទាក់ទងនឹងការគ្រប់គ្រងករណីសង្គ្រោះបន្ទាន់។




*រូបភាពទី៧៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង*

## ៥.៦. ការបណ្តុះបណ្តាល អភិបាល តាមដាន និងវាយតម្លៃ

ដើម្បីធានាឱ្យការផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ដំណើរការប្រកបដោយគុណភាព និងសុវត្ថិភាព មន្ត្រីសុខាភិបាលដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ទាំងអស់ ត្រូវតែឆ្លងកាត់វគ្គបណ្តុះបណ្តាលត្រឹមត្រូវ ព្រមទាំងមានការចុះអភិបាលគាំទ្របច្ចេកទេស ការតាមដាន និងវាយតម្លៃនៅតាមកន្លែងចាក់វ៉ាក់សាំងនីមួយៗឱ្យបានត្រឹមត្រូវ និងទៀងទាត់តាមកាលកំណត់។

មន្ត្រីសម្របសម្រួល និងទទួលបន្ទុកគ្រប់គ្រងកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩នីមួយៗ ត្រូវចុះអភិបាល និងផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមការងារចាក់វ៉ាក់សាំងជាប្រចាំ ដោយប្រើបញ្ជីផ្ទៀងផ្ទាត់គំរូសម្រាប់អ្នកអភិបាលនៅកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩ ដូចក្នុង**ឧបសម្ព័ន្ធ គ**។

បន្ថែមពីលើការអភិបាលជាប្រចាំ ត្រូវមានការចុះវាយតម្លៃនៅតាមកន្លែងចាក់វ៉ាក់សាំងនីមួយៗ ជារៀងរាល់ត្រីមាស ឬ ឆមាស (ឬតាមការចាំបាច់) ដោយមន្ត្រីទទួលបន្ទុកការងារចាក់វ៉ាក់សាំងកូវីដ-១៩នៅថ្នាក់ជាតិ ថ្នាក់មន្ទីរសុខាភិបាលខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ (ឬមណ្ឌលសុខភាព)។ ការវាយតម្លៃនេះត្រូវធ្វើឡើងឱ្យបានហ្មត់ចត់ទៅលើការងាររៀបចំកន្លែងចាក់វ៉ាក់សាំង ដំណើរការ និងសកម្មភាពភាពបច្ចេកទេសរបស់ក្រុមការងារផ្តល់សេវាចាក់វ៉ាក់សាំងនៅគ្រប់ផ្នែកទាំងអស់ ព្រមទាំងកត់ត្រារាល់បញ្ហា និងមូលហេតុពាក់ព័ន្ធនានាដែលរក

ឃើញនៅពេលចុះវាយតម្លៃ ដោយប្រើឧបករណ៍វាយតម្លៃក្រោយវគ្គបណ្តុះបណ្តាលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូចក្នុង **ឧបសម្ព័ន្ធ ឃ**។ ក្រៅពីនេះ ត្រូវមានការតាមដានជាប្រចាំ ដោយផ្តោតលើសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិចត្រឹមត្រូវ ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំង គឺមានភាពចាំបាច់ណាស់ក្នុងការតាមដានវឌ្ឍនភាព។ ដូច្នេះប្រធានក្រុម និងអ្នកសម្របសម្រួលទាំងអស់ត្រូវមានបញ្ជីអ្នកទទួលបានវ៉ាក់សាំងទាំងពីរដូស និងអត្រាគ្របដណ្តប់ ។
- ការផ្ញើរបាយការណ៍តាមដានសម្រាប់អង្គភាពសុខាភិបាលថ្នាក់ក្រោមជាតិ សូមមើលរូបភាពទី៨។ សម្រាប់មន្ទីរពេទ្យជាតិ ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើរបាយការណ៍ផ្ទាល់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ឬ ក្រសួងសុខាភិបាលតែម្តង។
- សូចនាករសម្រាប់តាមដានរួមមាន៖
  - ✓ ចំនួន ឬ ភាគរយនៃប្រជាជននៅក្នុងក្រុមគោលដៅនីមួយៗ ដែលបានទទួលវ៉ាក់សាំងលើកទី១
  - ✓ ចំនួន ឬ ភាគរយនៃប្រជាជននៅក្នុងក្រុមគោលដៅនីមួយៗ ដែលបានទទួលវ៉ាក់សាំងលើកទី២
  - ✓ សមាមាត្រប្រជាជនក្នុងក្រុមគោលដៅដែលបានទទួលដូសទី១ ប៉ុន្តែមិនបានទទួលដូសទី២តាមកាលវិភាគ
  - ✓ ចំនួន ឬ ភាគរយនៃប្រជាជននៅក្នុងក្រុមគោលដៅនីមួយៗដែលបានទទួលវ៉ាក់សាំងទាំងពីរដូស តាមខេត្ត និងតាមការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ
  - ✓ ចំនួន ឬ ភាគរយនៃស្ត្រីភេទនៅក្នុងក្រុមគោលដៅនីមួយៗដែលបានទទួលវ៉ាក់សាំងទាំងពីរដូស




*រូបភាព៨៖ គំនូសបំព្រួញក្នុងការរាយការណ៍តាមលំដាប់ថ្នាក់*

# ឯកសារយោង


1. គោលការណ៍ណែនាំប្រតិបត្តិ សម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ របស់កម្មវិធីជាតិចាក់ថ្នាំបង្ការនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ២០២១
2. ផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ របស់កម្មវិធីជាតិចាក់ថ្នាំបង្ការនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ២០២១
3. ពិធីសារស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ របស់កម្មវិធីជាតិចាក់ថ្នាំបង្ការនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ២០២១
4. នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគជំងឺកូវីដ-១៩ នៅមូលដ្ឋានសុខាភិបាល និងកន្លែងថែទាំអ្នកជំងឺនៅកម្ពុជា របស់ក្រសួងសុខាភិបាល បោះពុម្ព ខែកក្កដា ឆ្នាំ២០២០
5. គោលការណ៍ណែនាំស្តីពី ការស្រាវជ្រាវបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ របស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ បោះពុម្ព ខែកក្កដា ឆ្នាំ២០១៥
6. អនុសាសន៍បណ្តោះអាសន្នរបស់អង្គការសុខភាពពិភពលោកសម្រាប់ការប្រើប្រាស់វ៉ាក់សាំង SII Covishield ដែលបានធ្វើបច្ចុប្បន្នភាព ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១: https://www.who.int/publications/i/item/WHO-2019-nCoV-vaccines-SAGE_recommendation-AZD1222-2021.1
7. អនុសាសន៍បណ្តោះអាសន្នរបស់អង្គការសុខភាពពិភពលោកសម្រាប់ការប្រើប្រាស់វ៉ាក់សាំង Sinopharm បោះពុម្ព ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១: file:///C:/Users/User/AppData/Local/Temp/WHO-2019-nCoV-vaccines-SAGE-recommendation-BIBP-2021.1-eng.pdf
8. អនុសាសន៍បណ្តោះអាសន្នរបស់អង្គការសុខភាពពិភពលោកសម្រាប់ការប្រើប្រាស់វ៉ាក់សាំង Sinovac បោះពុម្ព ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១: https://apps.who.int/iris/bitstream/handle/10665/341454/WHO-2019-nCoV-vaccines-SAGE-recommendation-Sinovac-CoronaVac-2021.1-eng.pdf

# ឧបសម្ព័ន្ធ ក

**ស្ថិតិឥស្សរជន/ប្រជាជន ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩**

ប្រចាំថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ គិតត្រឹមម៉ោង ៥:០០នាទី ល្ងាច

| ល.រ | កន្លែងចាក់វ៉ាក់សាំង | ក្រុមអាយុ | ការចាក់លើកទី១ | | | | | | | | | | ការចាក់លើកទី២ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | | | 2 | | | 3 | | | 4 | 5 | | | 6 |
| | | | ចំនួនអ្នកបានចុះឈ្មោះ | | | ចំនួនអ្នកបានចាក់វ៉ាក់សាំង | | | ចំនួនអ្នកមិនបានចាក់វ៉ាក់សាំង | | | ប្រភេទវ៉ាក់សាំង | ចំនួនអ្នកបានចាក់វ៉ាក់សាំង | | | ប្រភេទវ៉ាក់សាំង |
| | | | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | SARS-CoV-2 | សរុប | ស្រី | ប្រុស | SARS-CoV-2 |
| 1 | មន្ទីរពេទ្យ............................ | | | | | | | | | | | Sinopharm/Beijing | | | | Sinopharm/Beijing |
| | | | | | | | | | | | | Sinovac/Biotech | | | | Sinovac/Biotech |
| | | | | | | | | | | | | Covishield™ | | | | Covishield™ |
| 2 | មន្ទីរពេទ្យ............................ | | | | | | | | | | | Sinopharm/Beijing | | | | Sinopharm/Beijing |
| | | | | | | | | | | | | Sinovac/Biotech | | | | Sinovac/Biotech |
| | | | | | | | | | | | | Covishield™ | | | | Covishield™ |
| 3 | មន្ទីរពេទ្យ............................ | | | | | | | | | | | Sinopharm/Beijing | | | | Sinopharm/Beijing |
| | | | | | | | | | | | | Sinovac/Biotech | | | | Sinovac/Biotech |
| | | | | | | | | | | | | Covishield™ | | | | Covishield™ |
| សរុប Sinopharm/Beijing | | | | | | | | | | | | Sinopharm/Beijing | | | | Sinopharm/Beijing |
| សរុប Sinovac/Biotech | | | | | | | | | | | | Sinovac/Biotech | | | | Sinovac/Biotech |
| សរុប Covishield™ | | | | | | | | | | | | Covishield™ | | | | Covishield™ |
| សរុបរួមទូទាំងមន្ទីរសុខាភិបាល | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | 0 | 0 | 0 | |

ថ្ងៃសៅរ៍ ០៧កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១

**បានឃើញ និងឯកភាព**
**ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ**

**បានពិនិត្យត្រឹមត្រូវ**
ប្រធានការិយាល័យបង្ការ និងគ្រប់គ្រងជំងឺ

ប្រធានកម្មវិធីផ្តល់ថ្នាំបង្ការ

ចំនួនអ្នកមិនបានចាក់សរុប៖ សរុប............ ស្រី............... ប្រុស..................

មិនស្ម័គ្រចិត្តចាក់៖ សរុប............ ស្រី............... ប្រុស..................

មិនអាចចាក់បាន៖ សរុប............ ស្រី............... ប្រុស..................

មូលហេតុ

១ ..................... នាក់

២ ..................... នាក់

៣ ..................... នាក់

## ឧបសម្ព័ន្ធ ខ

សម្ភារៈបរិក្ខារដែលចាំបាច់ត្រូវមាននៅក្នុងកញ្ចប់ឃីតរួមមាន៖

-Adrenaline ( 1:1,000 = 1 mg/ 1 ml ) ចំនួន ១ អំពូល

-Adrenaline ( 1:10,000 = 1 mg/ 10 ml ) ចំនួន ២ អំពូល

-កញ្ចប់សំឡីអាកុលសម្រាប់ជូតសម្លាប់មេរោគ ២ សន្លឹក

-សឺរ៉ាំងចំណុះ 1 ml ចំនួន ២

-ម្ជុលលេខ 18 ឬ19 ចំនួន ២

-ម្ជុលលេខ 23 × 32 mm ចំនួន ១

-តារាងណែនាំកម្រិតប្រើថ្នាំ Adrenaline ឬ Epinephrine ដែលត្រូវមានអ៊ិតប្លាស្ទិចត្រឹមត្រូវ

**សម្ភារៈបរិក្ខារបន្ថែមអាចមាន៖**

-Anti-histamines

-Steroids

-សេរ៉ូម Dextrose ( 50% ) ampules

-សឺរ៉ាំង ១០ CC

-សេរ៉ូមប្រៃធម្មតា

-ឧបករណ៍សង្គ្រោះដង្ហើម

-ម៉ាស់ហោប៉ៅ ( Bag mask )

-ស្តេតូស្កុប និងប្រដាប់វាស់សម្ពាធឈាម

-ប្រដាប់សង្កត់អណ្តាត និងកន្ត្រៃ

-ខ្សែបង្ហូរសេរ៉ូម និងសម្ភារៈដែលត្រូវការផ្សេងទៀត ដូចជាឧបករណ៍ចងរឹតដៃ

-ខ្យល់អុកស៊ីហ្សែន និងឧបករណ៍ដែលត្រូវការដើម្បីផ្តល់អុកស៊ីហ្សែន

## ឧបសម្ព័ន្ធ គ

**បញ្ជីផ្ទៀងផ្ទាត់សម្រាប់អភិបាលនៅកន្លែងចាក់វ៉ាក់សាំងកូវីដ-១៩**

ទីកន្លែងចាក់វ៉ាក់សាំង៖ ..............................................................................

ស្រុក/ខណ្ឌ៖ .......................................... រាជធានី/ខេត្ត៖ ..........................................

ក្រុមត្រួតពិនិត្យទី៖ .......................................... កាលបរិច្ឆេទ៖ ..........................................

| ល.រ | ចំណុចសំខាន់ៗដែលត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ | មាន/គ្មាន | មតិយោបល់ផ្សេងៗ |
|---|---|---|---|
| I | **ការរៀបចំកន្លែងចាក់វ៉ាក់សាំងជាទូទៅ** | | |
| 1 | បានរៀបចំទីតាំងចាក់វ៉ាក់សាំង ត្រឹមត្រូវតាមរូបភាពមគ្គុទេសន៍ដែលបានណែនាំក្នុងនីតិវិធីប្រតិបត្តិស្តង់ដា | | |
| 2 | មានក្រុមការងារចាក់វ៉ាក់សាំងដែលបានបណ្តុះបណ្តាលគ្រប់ចំនួន | | |
| 3 | មានសម្ភារបរិក្ខាចាំបាច់ ( គិតទាំងវ៉ាក់សាំង ឧបករណ៍ការពារខ្លួន ) សម្រាប់ប្រើប្រាស់នៅតាមផ្នែកនិមួយៗ | | |
| 4 | ដំណើរការផ្តល់ការចាក់វ៉ាក់សាំងចាប់ផ្តើមទាន់ពេល | | |
| II | **ច្រកចូលបរិវេណចាក់វ៉ាក់សាំង** | | |
| 1 | មានកន្លែងបាញ់អាល់កុល ( ឡាវ៉ាបូនិងសាប៊ូ ) សម្រាប់លាងដៃ | | |
| 2 | អ្នកចូលចាក់វ៉ាក់សាំងមានពាក់ម៉ាស់ត្រឹមត្រូវ | | |
| 3 | បានវាស់កំដៅមុនអនុញ្ញាតឱ្យចូល | | |
| III | **ផ្នែករង់ចាំរួមមុនចូលចាក់វ៉ាក់សាំង** | | |
| 1 | មានបញ្ជីឈ្មោះដែលបានផ្តល់ដោយអាជ្ញាធរ ឬមន្ត្រីសម្របសម្រួល | | |
| 2 | បានផ្ទៀងផ្ទាត់បញ្ជីឈ្មោះ អាយុ អត្តសញ្ញាណប័ណ្ណ និងវ័យមនុស្សជាក់ស្តែង | | |
| 3 | មន្ត្រីសុខាភិបាលបានគ្រប់គ្រងនូវភាពកកកុញ | | |
| 5 | មានអ្នកមកចាក់វ៉ាក់សាំងអង្គុយរង់ចាំ ដោយរក្សាបានគម្លាតសុវត្ថិភាព ( ១,៥ម៉ែត្រ ) | | |
| 6 | អ្នករង់ចាំមានពាក់ម៉ាស់ត្រឹមត្រូវ ( បើអត់ ត្រូវផ្តល់ជូនម៉ាស់ ) | | |
| 7 | មានមន្ត្រី ឬបុគ្គលិកត្រួតពិនិត្យ និងចែកលេខរៀងឱ្យចូល | | |
| IV | **ផ្នែកពិគ្រោះសុខភាព** | | |
| 1 | គ្រូពេទ្យសាកសួរពីប្រវត្តិជំងឺ និងពិនិត្យសុខភាពតាមបច្ចេកទេស (ដោយយោងលើ**ឯកសារជំនួយស្មារតី** ) | | |
| 2 | គិលានុប្បដ្ឋាកវាស់សម្ពាធឈាម និងយកសញ្ញាជីវិត (តាមករណីចាំបាច់ ឬការណែនាំគ្រូពេទ្យ) | | |
| 3 | អ្នកចូលចាក់វ៉ាក់សាំងបានចុះហត្ថលេខាលើទម្រង់កិច្ចព្រមព្រៀងចាក់វ៉ាក់សាំង | | |
| 4 | បានអនុវត្តវិធានអនាម័យ៖ គ្រូពេទ្យ និងគិលានុប្បដ្ឋាកមានពាក់ម៉ាស់ និងលាងដៃជាមួយអាល់កុលមុនពេលប៉ះពាល់អតិថិជន និងអង្គុយរក្សាគម្លាតសុវត្ថិភាពត្រឹមត្រូវ ( ១,៥ម៉ែត្រ ) | | |

| | | | |
|---|---|---|---|
| V | **ផ្នែកចុះឈ្មោះនិងកត់ត្រាព័ត៌មាន** | | |
| 1 | មានបញ្ជីឈ្មោះដែលបានផ្ដល់ដោយអាជ្ញាធរ ឬមន្ត្រីសម្របសម្រួល | | |
| 2 | បានថតរូប និងចុះឈ្មោះចូលក្នុងប្រព័ន្ធចុះឈ្មោះអេឡិចត្រូនិក ឬលើក្រដាសទម្រង់ចុះឈ្មោះ | | |
| 3 | បានថតអត្តសញ្ញាណប័ណ្ណ ភ្ជាប់និងប័ណ្ណចាក់វ៉ាក់សាំង | | |
| 4 | បានសរសេរឬបោះពុម្ពព័ត៌មានអ្នកចាក់វ៉ាក់សាំងលើប័ណ្ណចាក់វ៉ាក់សាំង | | |
| VI | **ផ្នែកចាក់វ៉ាក់សាំង** | | |
| 1 | បានចាក់វ៉ាក់សាំងតាមបច្ចេកទេសត្រឹមត្រូវ (៩០ដឺក្រេ) | | |
| 2 | បានអនុវត្តវិធានអនាម័យ៖ គ្រូពេទ្យ និងគិលានុបដ្ឋាកមានពាក់ម៉ាស់ និងលាងដៃជាមួយអាល់កុលមុនពេលប៉ះពាល់អតិថិជន និងអង្គុយរក្សាគម្លាតសុវត្ថិភាពត្រឹមត្រូវ (១,៥ម៉ែត្រ) | | |
| 3 | មានប្រអប់សុវត្ថិភាពសម្រាប់ដាក់សឺរ៉ាំងម្ជុល និងប្រើប្រាស់បានត្រឹមត្រូវ | | |
| 4 | មានធុងសំណល់ឆ្លងរោគ (លឿង) និងធុងសំណល់ទូទៅ (បៃតង) និងប្រើប្រាស់បានត្រឹមត្រូវ | | |
| VII | **ផ្នែករង់ចាំក្រោយចាក់វ៉ាក់សាំង** | | |
| 1 | មានកន្លែងអង្គុយរង់ចាំ ដែលមានគម្លាតសុវត្ថិភាពត្រឹមត្រូវ (១,៥ម៉ែត្រ) | | |
| 2 | មានមន្ត្រីសុខាភិបាលសង្កេតអ្នករង់ចាំក្រោយចាក់វ៉ាក់សាំង | | |
| 3 | អ្នកចាក់វ៉ាក់សាំងរួចរង់ចាំ ៣០នាទី | | |
| 4 | អ្នកចាក់វ៉ាក់សាំងរួចបានទទួលប័ណ្ណចាក់វ៉ាក់សាំង | | |
| VIII | **ផ្នែកសង្គ្រោះបន្ទាន់** | | |
| 1 | មានកញ្ចប់ឃីតសង្គ្រោះបន្ទាន់ តាមការណែនាំ | | |
| 2 | មានប្រព័ន្ធបញ្ជូន៖ គ្រែរុញបញ្ជូន ឬរថយន្តគិលានសង្គ្រោះប្រចាំការសម្រាប់អ្នកមកចាក់វ៉ាក់សាំងដែលមានបញ្ហាធ្ងន់ធ្ងរក្រោយចាក់ | | |
| 3 | មានគ្រូពេទ្យប្រចាំការដើម្បីផ្ដល់ការពិនិត្យ ថែទាំ និងសង្គ្រោះបន្ទាន់ដល់អ្នកចាក់វ៉ាក់សាំងដែលមានបញ្ហាក្រោយចាក់វ៉ាក់សាំង | | |

## ឧបសម្ព័ន្ធ ឃ

# ឧបករណ៍វាយតម្លៃក្រោយវគ្គបណ្តុះបណ្តាលការចាក់វ៉ាក់សាំងកូវីដ-១៩

**ក. ឈ្មោះមន្ត្រីចុះវាយតម្លៃ៖**

1. ........................................................ តួនាទី៖........................................................
2. ........................................................ តួនាទី៖........................................................
3. ........................................................ តួនាទី៖........................................................

**ខ. ទីតាំងចុះវាយតម្លៃ៖**

រាជធានី/ខេត្ត៖........................................................ ស្រុកប្រតិបត្តិ៖........................................................

មណ្ឌលសុខភាព៖........................................................ ឈ្មោះទីតាំង៖........................................................

**គ. ថ្ងៃចុះវាយតម្លៃ៖**........../........../..........

**ឃ. ការវាយតម្លៃកន្លែងចាក់វ៉ាក់សាំង៖**

១. តើការរៀបចំហ្វូងប្រជាជនមកទទួលវ៉ាក់សាំងបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

២. តើប្រជាជនមកទទួលវ៉ាក់សាំងទាំងអស់មានពាក់ម៉ាស់ រក្សាគម្លាត លាងដៃ និងវាស់កំដៅដែរឬទេ? ☐បាន / ☐ទេ

៣. តើប្រជាជនឈរតម្រង់ជួរបានត្រឹមត្រូវតាមការណែនាំដែរឬទេ? ☐បាន / ☐ទេ

**ង. ការវាយតម្លៃការចូលរួមសម្របសម្រួលពីអាជ្ញាធរ/ផ្នែកពាក់ព័ន្ធនៅកន្លែងចាក់វ៉ាក់សាំង៖**

១. តើមានការចូលរួមសម្របសម្រួលពីអាជ្ញាធរនៅតាមទីតាំងនីមួយៗបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

២. តើមានផែនការ និងកម្មវិធី ក្នុងការជូនដំណឹង/អញ្ជើញប្រជាជនមកទទួលវ៉ាក់សាំងដែរឬទេ? ☐បាន / ☐ទេ

**ច. ការវាយតម្លៃក្រុមមន្ត្រីពិគ្រោះមុនចាក់វ៉ាក់សាំង៖**

១. តើការពិគ្រោះមុនចាក់វ៉ាក់សាំងធ្វើបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

២. តើដំណើការនៃការពិគ្រោះ និងជ្រើសរើសអតិថិជនមិនមានភាពកកស្ទះដែរឬទេ? ☐បាន / ☐ទេ

៣. តើគម្លាតរវាងប្រជាជន និងមន្ត្រីត្រូវបានរក្សាដែរឬទេ? ☐បាន / ☐ទេ

**ឆ. ការវាយតម្លៃក្រុមមន្ត្រីកត់ត្រាព័ត៌មានក្នុងប្រព័ន្ធ មុនចាក់វ៉ាក់សាំង៖**

១. តើទីតាំងកត់ត្រាព័ត៌មានស្ថិតនៅមុនទីតាំងចាក់វ៉ាក់សាំងដែរឬទេ? ☐បាន / ☐ទេ

២. តើដំណើការនៃការកត់ត្រាព័ត៌មានអតិថិជនមិនមានភាពកកស្ទះដែរឬទេ? ☐បាន / ☐ទេ

៣. តើគម្លាតរវាងប្រជាជន និងមន្ត្រីត្រូវបានរក្សាដែរឬទេ? ☐បាន / ☐ទេ

**ជ. ការវាយតម្លៃក្រុមមន្ត្រីចាក់វ៉ាក់សាំង៖**

១. តើទីតាំងចាក់វ៉ាក់សាំង ស្ថិតនៅបន្ទាប់ពីទីតាំងកត់ត្រាព័ត៌មានអតិថិជនដែរឬទេ? ☐បាន / ☐ទេ

២. តើដំណើការនៃការចាក់វ៉ាក់សាំង មិនមានភាពកកស្ទះដែរឬទេ? ☐បាន / ☐ទេ

៣. តើបច្ចេកទេសទុកដាក់ និងថែរក្សាវ៉ាក់សាំងអនុវត្តបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ



ងៃ

៤. តើបច្ចេកទេសបូមវ៉ាក់សាំងពីដប និង ចាក់វ៉ាក់សាំងបានអនុវត្តត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

៥. តើការប្រើប្រាស់ និង ទុកដាក់ប្រអប់សុវត្ថិភាពប្រើរួចបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

៦. តើបានប្រើសំឡីទឹកស្អាត សម្រាប់សំអាតស្បែកមុនចាក់ដែរឬទេ?

## ឈ. ការវាយតម្លៃកន្លែងរង់ចាំ ៣០នាទី ក្រោយចាក់វ៉ាក់សាំង៖

១. តើដំណើការនៃការរង់ចាំ ៣០នាទី ក្រោយចាក់ អនុវត្តបានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

២. តើមានពេទ្យប្រចាំការដែរឬទេ? ☐បាន / ☐ទេ

៣. តើមានឱសថសង្គ្រោះបឋមគ្រប់គ្រាន់, បំពង់អុកស៊ីសែន គ្រែ និងទីតាំងសមរម្យដែរឬទេ? ☐បាន / ☐ទេ

៤. ក្នុងករណីមានហេតុការណ៍ AEFI តើបុគ្គលិកបានទំនាក់ទំនង និងរាយការណ៍ទាន់ពេលដែរឬទេ? ☐បាន / ☐ទេ

## ញ. ការវាយតម្លៃការគ្រប់គ្រងសំណល់នៅកន្លែងចាក់វ៉ាក់សាំង៖

១. នៅពេលកំពុងដំណើរការចាក់វ៉ាក់សាំង តើការរៀបចំសំណល់បានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

២. នៅពេលចប់ការចាក់វ៉ាក់សាំងនៃថ្ងៃនីមួយៗ តើការទុកដាក់សំណល់បានត្រឹមត្រូវដែរឬទេ? ☐បាន / ☐ទេ

## ដ. បញ្ហា និងមូលហេតុដែលសង្កេតឃើញនៅពេលចុះវាយតម្លៃ៖

| បញ្ហា/ឧបសគ្គ | មូលហេតុជាក់ស្តែង | ដំណោះស្រាយសមស្រប |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

## ឆ. សំណូមពររបស់មូលដ្ឋាន៖

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

ថ្ងៃទី ........./........./ ២០២......

ហត្ថលេខា និងឈ្មោះមន្ត្រីចុះវាយតម្លៃ